Australian Government
Medicare Australia

# កម្មវិធីឯទៀតរបស់មេឌីឃែរអូស្ត្រាលី

# ផែនការមើលថែធ្មេញយុវវ័យរបស់មេឌីឃែរ

## តើផែនការមើលថែធ្មេញយុវវ័យរបស់មេឌីឃែរគឺជាអ្វី?

រដ្ឋាភិបាលអូស្ត្រាលីបានដាក់ឲ្យមានផែនការមើលថែធ្មេញយុវវ័យរបស់មេឌីឃែរ ដើម្បីជួយចេញថ្លៃចំណាយលើការឆែកមើលធ្មេញដើម្បីបង្ការប្រចាំឆ្នាំ សំរាប់យុវជនមានសិទ្ធិទទួលដែលមានអាយុ 12–17 ឆ្នាំ។

## តើខ្ញុំមានសិទ្ធិទទួលផែនការមើលថែធ្មេញយុវវ័យរបស់មេឌីឃែរឬទេ?

អ្នកមានសិទ្ធិទទួលផែនការមើលថែធ្មេញយុវវ័យរបស់មេឌីឃែរ ហើយអាចទទួលការឆែកមើលធ្មេញដើម្បីបង្ការ បើអ្នកជាយុវជន៖

- មានអាយុ 12–17 ឆ្នាំ
- ទទួលប្រាក់ជំនួយ Abstudy, ប្រាក់ជំនួយសំរាប់អ្នកថែទាំ (Carer Payment), ប្រាក់សោធនឧបត្ថម្ភអ្នកមានពិការភាព (Disability Support Pension), ប្រាក់ជំនួយសំរាប់មាតាបិតា (Parenting Payment), ប្រាក់ជំនួយពិសេស (Special Benefit) ឬប្រាក់ជំនួយយុវជន (Youth Allowance); ឬ
- មានគ្រួសារ ឬអ្នកថែទាំ ឬអ្នកអាណាព្យាបាលទទួលប្រាក់បំណាច់ពន្ធដារគ្រួសារផ្នែក A (FTB-A), ប្រាក់ជំនួយសំរាប់មាតាបិតា ឬប្រាក់សោធនសំរាប់ក្មេងកំព្រាឪពុកម្តាយ(Double Orphan Pension) សំរាប់ខ្លួនអ្នក; ឬ
- មានគូកំណាន់ទទួល FTB-A ឬប្រាក់ជំនួយសំរាប់មាតាបិតា; ឬ
- មានអាយុចាប់ពី 16 ឡើងទៅ ហើយទទួលជំនួយប្រាក់កាសនៅក្រោមគម្រោងសិក្សាសំរាប់កូនរបស់អតីតយុទ្ធជន (Veterans' Children Education Scheme - VCES) ឬគម្រោងសិក្សាអប់រំ និងបណ្តុះបណ្តាលនៃច្បាប់កាយនីតិសម្បទា និងសងទូទាត់យុទ្ធជន (Military Rehabilitation and Compensation Act Education and Training Scheme - MRCAETS)
- មានសិទ្ធិទាមទារសុំប្រាក់បំណាច់ Medicare (មេឌីឃែរ)។

## តើផែនការមើលថែធ្មេញយុវវ័យរបស់មេឌីឃែរ មានដំណើរការយ៉ាងដូចម្តេច?

បើអ្នកមានសិទ្ធិទទួលផែនការនេះ អ្នក ឬមាតា ឬបិតា ឬអ្នកថែទាំរបស់អ្នកនឹងទទួលលិខិត និងប័ណ្ណតំណាងប្រាក់អំពីសិទ្ធិទទួលការឆែកមើលធ្មេញដើម្បីបង្ការ។ បើអ្នកស្ថិតនៅក្នុងការរៀបចំថែទាំរួមស្មើគ្នា នោះគេនឹងផ្ញើលិខិតមួយ និងប័ណ្ណតំណាងប្រាក់ទៅជូនមាតាបិតា ឬអ្នកថែទាំរបស់អ្នក។

### តើប័ណ្ណតំណាងប្រាក់គឺសំរាប់អ្វី?

ប័ណ្ណតំណាងប្រាក់នេះអនុញ្ញាតឲ្យអ្នកទាមទារសុំប្រាក់បំណាច់ពី Medicare នៅរៀងរាល់ឆ្នាំ នៅពេលដែលអ្នកបានទៅជួបគ្រូពេទ្យធ្មេញ និងមានការឆែកមើលធ្មេញដើម្បីបង្ការ។ ប័ណ្ណតំណាងប្រាក់នេះគួរផ្តល់ឲ្យគ្រូពេទ្យធ្មេញនៅពេលដែលអ្នកទទួលការឆែកមើលធ្មេញដើម្បីបង្ការរបស់អ្នក។ ប័ណ្ណតំណាងប្រាក់នេះបង្ហាញគ្រូពេទ្យធ្មេញថាអ្នកមានសិទ្ធិទទួលការឆែកមើលធ្មេញដើម្បីបង្ការ នៅក្រោមផែនការមើលថែធ្មេញយុវវ័យរបស់មេឌីឃែរ។ ប័ណ្ណតំណាងប្រាក់ទាំងឡាយអាចយកជាការបានសំរាប់អ្នកមានឈ្មោះនៅលើប័ណ្ណនោះតែប៉ុណ្ណោះ ហើយមិនអាចផ្ទេរទៅឲ្យអ្នកណាម្នាក់ទៀតបានទេ។

## តើខ្ញុំគួរធ្វើអ្វី បើខ្ញុំមិនបានទទួលប័ណ្ណតំណាងប្រាក់ទេ?

បើអ្នកយល់ថា អ្នកមានសិទ្ធិទទួលប័ណ្ណតំណាងប្រាក់ ហើយមិនបានទទួលវាទេ ឬអ្នកបានបាត់វាទៅហើយនោះ អ្នកអាច ទូរស័ព្ទលេខ **132 011*** ឬអញ្ជើញទៅការិយាល័យ Medicare ណាមួយ។

## តើការឆែកមើលធ្មេញដើម្បីបង្ការជាអ្វី?

ការឆែកមើលធ្មេញដើម្បីបង្ការត្រូវតែមានការឆែកពិនិត្យមើលក្នុងមាត់។ គ្រូពេទ្យធ្មេញរបស់អ្នកក៏អាច៖

- ថតកម្មរស្មីអិក្ស
- ផ្តល់ការកោស ហើយលាងសម្អាត
- ផ្តល់ការព្យាបាលហ្លូរីដ
- ផ្តល់ឲ្យអ្នកនូវការណែនាំអំពីអនាម័យមាត់
- ផ្តល់ឱវាទអំពីចំណីអាហារ
- បិទប្រហោង ឬស្នាមប្រេះនៃធ្មេញ (ការបិទស្នាមប្រេះតូចៗ)។

សេវា (កិច្ចបំរើ) ទាំងអស់នេះត្រូវបានរួមបញ្ចូលគ្នា ហើយអាចធ្វើទៅនៅក្នុងពេលជាច្រើនថ្ងៃ ហើយមិនអាចគិតថ្លៃដាច់ដោយឡែកពីគ្នាបានទេ ឬក៏រហូតទាល់តែបានព្យាបាលអ្នកបានចប់សព្វគ្រប់។

## តើខ្ញុំទទួលការឆែកមើលធ្មេញដើម្បីបង្ការដោយវិធីណា?

នៅពេលដែលអ្នកបានទទួលប័ណ្ណតំណាងប្រាក់របស់អ្នកហើយ ជំហានទាំងឡាយតទៅនេះនឹងជួយអ្នកក្នុងការទទួលប្រាក់បំណាច់របស់អ្នក។

### ជំហានទី 1 – ធ្វើការណាត់ជួបមួយគ្រូពេទ្យធ្មេញ

នៅពេលធ្វើការណាត់ជួបជាមួយគ្រូពេទ្យធ្មេញ អ្នកនឹងត្រូវឆែកមើលថា៖

- គ្រូពេទ្យធ្មេញនេះនឹងផ្តល់ការឆែកមើលធ្មេញដើម្បីបង្ការ នៅក្រោមផែនការមើលថែធ្មេញយុវវ័យរបស់មេឌីឃែរ ដែរឬទេ
- តើគ្រូពេទ្យធ្មេញនេះនឹងតម្រូវឲ្យអ្នកបង់ប្រាក់ជាមុនឬទេ និងថាតើនឹងអស់ថ្លៃច្រើនជាងប្រាក់បំណាច់ដែលអាចទាមទារសុំបានពី Medicare Australia ដែរឬទេ។

បើអ្នកមានសិទ្ធិទទួលសេវាធ្មេញសាធារណៈ អ្នកក៏អាចទូរស័ព្ទទៅកាន់គ្លីនិកធ្មេញសាធារណៈនៅក្បែរអ្នក (មានរួមទាំងគ្លីនិក តាមសាលារៀន) ដើម្បីឆែកមើលថា តើគ្លីនិកនោះផ្តល់ការឆែកមើលធ្មេញដើម្បីបង្ការឬទេ។

### ជំហានទី 2 – ទទួលការឆែកមើលធ្មេញដើម្បីបង្ការ

អ្នកនឹងត្រូវយកប័ណ្ណតំណាងប្រាក់របស់អ្នកទៅកាន់គ្រូពេទ្យធ្មេញ នៅពេលដែលអ្នកទទួលការឆែកមើលធ្មេញដើម្បីបង្ការ។

### ជំហានទី 3 – ការទាមទារសុំប្រាក់បំណាច់ឆែកមើលធ្មេញដើម្បីបង្ការរបស់អ្នក

ក្រោយពីការឆែកមើលធ្មេញដើម្បីបង្ការរបស់អ្នកហើយ គ្រូពេទ្យធ្មេញនឹងទារប្រាក់ពីអ្នកតាមវិធីមួយក្នុងចំណោមវិធីបីយ៉ាង។

1. គ្រូពេទ្យធ្មេញនឹងគិតថ្លៃដោយផ្ទាល់ (bulk bill) ចំពោះសេវានេះ ដោយសុំឲ្យអ្នកចុះហត្ថលេខាលើពាក្យបំពេញការអនុញ្ញាតឲ្យទទួលប្រាក់បំណាច់ (Assignment of Benefit form) ដើម្បីឲ្យគ្រូពេទ្យធ្មេញទទួលប្រាក់បំណាច់ដោយផ្ទាល់ពី Medicare Australia ។

2. គ្រូពេទ្យធ្មេញនឹងសុំឲ្យអ្នកបង់ថ្លៃសេវានេះពេញលេញ។ អ្នកអាចទាមទារសុំប្រាក់បំណាច់របស់អ្នកតាមរយៈការដាក់ឯកសារពាក់ព័ន្ធនឹងថ្លៃចំណាយ ឬបង្កាន់ដៃរបស់អ្នកនៅឯការិយាល័យ Medicare នៅក្បែរអ្នក ឬតាមរយៈការផ្ញើតាមប៉ុស្តិ៍សំបុត្រ។

3. ៈគូពេទ្យធ្មេញនឹងផ្តល់ជូនអ្នកនូវវិក្កយបត្រមិនទាន់បង់ប្រាក់មួយ។ អ្នកនឹងត្រូវយកវិក្កយបត្រ ឬបង្កាន់ដៃរបស់អ្នកទៅកាន់ការិយាល័ Medicare នៅក្បែរអ្នក ឬផ្ញើវាទៅកាន់ Medicare Australia។ យើងនឹងផ្ញើសែកមួយដែលមានចំនួនប្រាក់បំណាច់ ហើយមានឈ្មោះគ្រូពេទ្យធ្មេញនេះនៅពីលើសែកនោះ។ អ្នកនឹងត្រូវផ្ញើសែកនេះទៅកាន់គ្រូពេទ្យធ្មេញ ព្រមជាមួយចំនួនចន្លោះណាមួយដែលអ្នកនៅជំពាក់។

## ព័ត៌មានសំខាន់

- បើអ្នកមានសិទ្ធិទទួលការឆែកមើលធ្មេញដើម្បីបង្ការ អ្នកអាចទៅជួបវេជ្ជបណ្ឌិតមុនពេលទទួលប័ណ្ណតំណាងប្រាក់សំរាប់ផែនការមើលថែធ្មេញយុវវ័យរបស់មេឌីឃែរ ប៉ុន្តែអ្នកមិនអាចទាមទារសុំប្រាក់បំណាច់ធ្មេញរបស់អ្នកពី Medicare Australia បានទេ លុះត្រាតែអ្នកបានទទួលប័ណ្ណតំណាងប្រាក់សំរាប់ឆ្នាំប្រក្រតិទិននោះរួចសិន។
- បើអ្នកជាយុវជននៅក្នុងការរៀបចំថែទាំរួមស្មើគ្នា គ្រួសារដំបូងដែលទាមទារសុំសេវាពី Medicare Australia នឹងមានសិទ្ធិទទួលប្រាក់បំណាច់មើលថែធ្មេញពេញលេញ។
- បើថ្លៃសរុបនៃការឆែកមើលធ្មេញដើម្បីបង្ការរបស់អ្នក មានចំនួនច្រើនជាងចំនួនទឹកប្រាក់នៃប័ណ្ណតំណាងប្រាក់របស់អ្នក Medicare Australia អាចបង់ថ្លៃតាមចំនួននៃប័ណ្ណតំណាងប្រាក់តែប៉ុណ្ណោះ។ អ្នកនឹងទទួលខុសត្រូវចំពោះចំនួនបន្ថែមណាមួយ។ បើថ្លៃសរុបមានចំនួនតិចជាងចំនួនទឹកប្រាក់នៃប័ណ្ណតំណាងប្រាក់របស់អ្នក Medicare Australia អាចបង់ចំនួនទឹកប្រាក់ដែលគិតថ្លៃដោយគ្រូពេទ្យធ្មេញតែប៉ុណ្ណោះ។
- ការឆែកមើលធ្មេញដើម្បីបង្ការគឺជាសេវាមួយរបស់ Medicare ដែលអាចទាមទារសុំប្រាក់បំណាច់ពី Medicare Australia ។ អ្នកអាចជ្រើសយកការទាមទារសុំតាមរយៈក្រុមហ៊ុនធានារ៉ាប់រងសុខភាពឯកជនរបស់អ្នក ប៉ុន្តែអ្នកមិនអាចទាមទារសុំប្រាក់ពីស្ថាប័នទាំងពីរឡើយ។

## បញ្ជីឆែកពិនិត្យដោយសង្ខេប

- រក្សាប័ណ្ណតំណាងប្រាក់ និងលិខិតរបស់អ្នកនៅក្នុងកន្លែងមានសុវត្ថិភាព។
- ធ្វើឲ្យច្បាស់ថាអ្នកយកប័ណ្ណតំណាងប្រាក់ និងប័ណ្ណ Medicare របស់អ្នកទៅជាមួយ នៅពេលអ្នកធ្វើដំណើរទៅជួបគ្រូពេទ្យធ្មេញ។
- ធ្វើឲ្យច្បាស់ថាអ្នកយកប័ណ្ណ Medicare របស់អ្នកទៅជាមួយ នៅពេលទាមទារសុំប្រាក់បំណាច់របស់អ្នកនៅការិយាល័យ Medicare ។
- ចងចាំក្នុងការប្រាប់ Medicare Australia, Centrelink ឬ DVA ឲ្យដឹង បើព័ត៌មានរបស់អ្នកមានការផ្លាស់ប្តូរនៅថ្ងៃមុខ។

## ដើម្បីទទួលព័ត៌មានបន្ថែម

| | |
|---|---|
| វិបសាយ | **www.medicareaustralia.gov.au**<br>**www.health.gov.au/dental** |
| ទូរស័ព្ទ | **132 011*** |
| TTY | **1800 552 152**** (សំរាប់អ្នកមានពិការភាពខាងស្តាប់ ឬនិយាយ) |
| TIS | **131 450*** (កិច្ចបំរើបកប្រែភាសាសរសេរ និងនិយាយ) |

# កម្មវិធីជាតិពិនិត្យរកមើលរោគមហារីកពោះវៀន

## តើកម្មវិធីជាតិពិនិត្យរកមើលរោគមហារីកពោះវៀនគឺជាអ្វី?

កម្មវិធីជាតិពិនិត្យរកមើលរោគមហារីកពោះវៀន មានគោលបំណងកាត់បន្ថយឧប្បត្តិហេតុ និងការស្លាប់ដោយសាររោគមហារីកពោះវៀន ដោយផ្តល់ជូនអ្នកមានអាយុ 50, 55 ឬ 65 ឆ្នាំ នៅចន្លោះអំឡុងពេលចាប់ពីខែមករា ឆ្នាំ 2008 ដល់ខែធ្នូ ឆ្នាំ 2010 នូវការពិនិត្យឆែកមើលរោគដោយប្រើតេស្តឆែករកមើលឈាមបង្កប់ក្នុងលាមក (FOBT) នៅកន្លែងផ្ទាល់ខ្លួនតាមផ្ទះរបស់អ្នកទាំងនោះផ្ទាល់។

## តើខ្ញុំមានសិទ្ធិចូលរួមក្នុងកម្មវិធីជាតិពិនិត្យរកមើលរោគមហារីកពោះវៀនឬទេ?

អ្នកដែលស្ថិតក្នុងរង្វង់មហាជនដែលមានសិទ្ធិទទួល នឹងត្រូវបានអញ្ជើញឲ្យចូលរួមក្នុងកម្មវិធីនេះ។ អ្នកមានសិទ្ធិទទួលគឺពលរដ្ឋអូស្ត្រាលីមានអាយុ 50, 55 ឬ 65 ឆ្នាំ នៅចន្លោះអំឡុងពេលចាប់ពីថ្ងៃទី 1 ខែមករា ឆ្នាំ 2008 ដល់ថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2010 ដែលមានប័ណ្ណ Medicare ឬប័ណ្ណមាស DVA ។

អ្នកមានទិដ្ឋាការបណ្តោះអាសន្ន និងអ្នករស់នៅជាបណ្តោះអាសន្ន នឹងគ្មានការអញ្ជើញឲ្យចូលរួមក្នុងកម្មវិធីនេះទេ ទោះជាអ្នកទាំងនោះស្ថិតនៅក្នុងរង្វង់អាយុដែលបានបញ្ជាក់ក៏ដោយ។

បើលោកអ្នកមានសិទ្ធិចូលរួមក្នុងកម្មវិធីនេះ លោកអ្នកនឹងទទួលលិខិតអញ្ជើញមួយតាមរយៈប៉ុស្តិ៍សំបុត្រ ដើម្បីបំពេញតេស្តសាមញ្ញមួយដែលហៅថា តេស្តរកមើលឈាមបង្កប់ក្នុងលាមក (FOBT) នៅកន្លែងផ្ទាល់ខ្លួនតាមផ្ទះរបស់លោកអ្នកផ្ទាល់ ហើយសំណាកនេះនឹងត្រូវបញ្ជូនទៅកាន់មន្ទីរពិសោធន៍រោគសាស្ត្រដើម្បីធ្វើការវិភាគ។ បើតេស្ត FOBT របស់លោកអ្នក បង្ហាញលទ្ធផលវិជ្ជមាន គេនឹងប្រាប់លោកអ្នកឲ្យពិភាក្សាលទ្ធផលនេះជាមួយវេជ្ជបណ្ឌិតរបស់លោកអ្នក ដែលជាទូទៅនឹងបញ្ជូនលោកអ្នកឲ្យទទួលការអង្កេតបន្ថែមទៀត ដូចជាការពិនិត្យពោះវៀនតាមរយៈបំពង់ស៊ើកឆ្លុះមើល (colonoscopy) ជាដើម។

## បញ្ជីចុះឈ្មោះជាតិពិនិត្យរកមើលរោគមហារីកពោះវៀន

Medicare Australia គ្រប់គ្រងបញ្ជីចុះឈ្មោះជាតិពិនិត្យរកមើលរោគមហារីកពោះវៀន។ បញ្ជីចុះឈ្មោះនេះចេញលិខិតអញ្ជើញឲ្យចូលរួមក្នុងកម្មវិធីនោះ កត់ត្រាព័ត៌មានរបស់អ្នកចូលរួមដោយមានរួមទាំងប្រវត្តិពិនិត្យរកមើលរោគ FOBT និងលទ្ធផលនៃការពិនិត្យពោះវៀនតាមរយៈបំពង់ស៊ើកឆ្លុះមើលជាដើម ព្រមទាំងការចេញលិខិតរំលឹកដល់អ្នកចូលរួម និងវេជ្ជបណ្ឌិត ឬគ្រូពេទ្យដែលជ្រើសតាំងរបស់អ្នកទាំងនោះ។

ព័ត៌មានផ្ទាល់ខ្លួន និងលទ្ធផលតេស្តទាំងឡាយត្រូវបានរក្សាទុកជាសម្ងាត់។ ច្បាប់ (ច្បាប់រក្សាការសម្ងាត់ ឆ្នាំ 1988) ការពារព័ត៌មានរក្សាទុកក្នុងបញ្ជីចុះឈ្មោះនោះ ហើយព័ត៌មានផ្ទាល់ខ្លួនត្រូវបានបញ្ចេញឲ្យដឹង ឲ្យសមស្របនឹងគោលការណ៍រក្សាទុកព័ត៌មានផ្ទាល់ខ្លួនរបស់ច្បាប់នេះ។

### តើព័ត៌មានអ្វីខ្លះដែលរក្សាទុកនៅក្នុងបញ្ជីចុះឈ្មោះនោះ?

បញ្ជីចុះឈ្មោះនេះរក្សាទុកព័ត៌មានទាំងឡាយដូចជា៖

- ព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នក ដូចជាឈ្មោះ ព័ត៌មានសំរាប់ទាក់ទង អាយុ និងភេទ
- លេខ Medicare របស់លោកអ្នក
- លទ្ធផលទាំងឡាយនៃការធ្វើតេស្តពិនិត្យរកមើលរោគ
- ឈ្មោះវេជ្ជបណ្ឌិតដែលជ្រើសតាំងរបស់លោកអ្នក
- លទ្ធផលនៃតេស្តបន្ថែមទៀតណាមួយដែលបានធ្វើឡើង ដូចជាការពិនិត្យពោះវៀនតាមរយៈបំពង់ស៊ើកឆ្លុះមើល ឬការពិនិត្យវិភាគជាលិកាជាដើម។

### តើគេនឹងប្រើព័ត៌មាននេះសំរាប់អ្វីទៅ?

Medicare Australia នឹងប្រើព័ត៌មានផ្ទាល់ខ្លួនទាំងឡាយដើម្បី៖

- អញ្ជើញអ្នកមានសិទ្ធិទទួលដើម្បីទៅពិនិត្យរកមើលរោគ
- រំលឹកអ្នកមានសិទ្ធិទទួលឲ្យបំពេញ FOBT របស់ខ្លួន
- ផ្តល់ព័ត៌មានសំរាប់ទាក់ទងទៅកាន់មន្ទីរពិសោធន៍រោគសាស្ត្រដែលទទួលខុសត្រូវចំពោះការវិភាគ FOBT ទាំងពួង
- ឆែកមើលពាក្យទាមទារសុំប្រាក់បំណាច់ Medicare និងក្រសួងកិច្ចការអតីតយុទ្ធជន (Department of Veterans Affairs) សំរាប់ការពិនិត្យពោះវៀន បើសិនជាត្រូវការ ហើយទាក់ទងអ្នកផ្តល់សេវាពិនិត្យព្យាបាលទាំងពួង ដើម្បីសុំឲ្យដាក់របាយការណ៍ពាក់ព័ន្ធនានាទៅកាន់បញ្ជីចុះឈ្មោះនេះ
- ផ្ញើលិខិតរំលឹក និង/ឬទូរស័ព្ទ (ពេលចាំបាច់) ទៅអ្នកចូលរួម និងវេជ្ជបណ្ឌិតដែលជ្រើសតាំងរបស់អ្នកទាំងនោះ។

ឈ្មោះ និងថ្ងៃខែឆ្នាំកំណើតរបស់លោកអ្នកនឹងត្រូវផ្តល់ទៅឲ្យវិជ្ជាស្ថានសុខភាព និងសុខុមាលភាពអូស្ត្រាលី (AIHW) សំរាប់គោលបំណងផ្ទៀងផ្ទាត់ទិន្នន័យការចុះឈ្មោះរោគមហារីក ដើម្បីបង្ហាញថាកម្មវិធីនេះកំពុងជួយសង្គ្រោះអាយុជីវិត។ ការផ្តល់ទិន្នន័យទៅឲ្យ AIHW គឺអាស្រ័យទៅនឹងមាត្រាលាក់ការសម្ងាត់ទាំងឡាយនៃច្បាប់វិជ្ជាស្ថានសុខភាព និងសុខុមាលភាពអូស្ត្រាលី ឆ្នាំ 1987។

ឈ្មោះ ព័ត៌មានសំរាប់ទាក់ទង និងព័ត៌មានអំពីការពិនិត្យរកមើលរោគ ក៏អាចផ្តល់ទៅឲ្យអ្នកជួយថែទាំព្យាបាលលោកអ្នកដែលពាក់ព័ន្ធនឹងការពិនិត្យរកមើលរោគមហារីកពោះវៀនផងដែរ ដោយមានរួមទាំង៖

- វេជ្ជបណ្ឌិតដែលជ្រើសតាំងរបស់លោកអ្នក
- អ្នកឯកទេសព្យាបាលទាំងឡាយដែលគេអាចបញ្ជូនលោកអ្នកឲ្យទៅជួប
- មន្ត្រីតាមពិនិត្យអ្នកចូលរួមនៅគ្រាបន្ទាប់មក
- បុគ្គលិកធ្វើការក្នុងផ្នែកពិនិត្យរកមើលរោគមហារីកពោះវៀនរបស់រដ្ឋាភិបាលថ្នាក់រដ្ឋ ឬដែនដី។

### តើអ្នកណានឹងអាចបើកមើល ឬទទួលព័ត៌មាននៅក្នុងបញ្ជីចុះឈ្មោះនេះ?

ព័ត៌មានដែលរក្សាទុកក្នុងបញ្ជីចុះឈ្មោះ ព្រមទាំងព័ត៌មានដែលផ្តល់ទៅកាន់ AIHW ដោយបញ្ជីចុះឈ្មោះ ត្រូវបានការពារដោយច្បាប់ ហើយនឹងមិនបញ្ចេញទៅឲ្យជន ឬអង្គការមួយផ្សេងទៀតដោយគ្មានការអនុញ្ញាតរបស់លោកអ្នកឡើយ ឬលុះត្រាតែតម្រូវ ឬអនុញ្ញាតដោយច្បាប់។

### តើព័ត៌មានអ្វីខ្លះដែលវេជ្ជបណ្ឌិត និងអ្នកឯកទេសព្យាបាលទាំងឡាយផ្តល់ទៅឲ្យបញ្ជីចុះឈ្មោះ?

វេជ្ជបណ្ឌិតព្យាបាលជំងឺទូទៅ និងអ្នកឯកទេសនឹងផ្តល់ព័ត៌មានទៅកាន់បញ្ជីចុះឈ្មោះ (តាមរយៈការបំពេញពាក្យប្រមូលទិន្នន័យ) អំពីការពិគ្រោះយោបល់ ឬទម្រង់ការទាំងឡាយជាមួយអ្នកចូលរួមក្នុងកម្មវិធី ដែលតេស្ត FOBT បង្ហាញលទ្ធផលវិជ្ជមាន។

## ដើម្បីទទួលព័ត៌មានបន្ថែម

| | |
|---|---|
| វិបសាយ | **www.medicareaustralia.gov.au**<br>**www.cancerscreening.gov.au** |
| ទូរស័ព្ទ | National Bowel Cancer Screening Register Information Line—**1800 118 868**** |
| TTY | **1800 552 152**** (សំរាប់អ្នកមានពិការភាពខាងស្តាប់ ឬនិយាយ) |

TIS 131 450* (កិច្ចបំរើបកប្រែភាសាសរសេរ និងនិយាយ)

*គិតថ្លៃទូរស័ព្ទ

**គិតថ្លៃទូរស័ព្ទចេញពីទូរស័ព្ទចល័ត និងទូរស័ព្ទដែលត្រូវបង់ថ្លៃសំរាប់ប្រើប៉ុណ្ណោះ។

# កម្មវិធីប្រាក់សំណងថ្លៃសុដន់សិប្បនិម្មិតខាងក្រៅ

## តើកម្មវិធីប្រាក់សំណងថ្លៃសុដន់សិប្បនិម្មិតខាងក្រៅគឺជាអ្វី?

កម្មវិធីប្រាក់សំណងថ្លៃសុដន់សិប្បនិម្មិតខាងក្រៅ (កម្មវិធី) គឺជាការផ្តួចផ្តើមមួយរបស់រដ្ឋាភិបាលអូស្ត្រាលី ដើម្បីផ្តល់ប្រាក់សំណងសំរាប់ការទិញសុដន់សិប្បនិម្មិតថ្មី ឬផ្លាស់ថ្មី ចំពោះស្ត្រីដែលមានការវះកាត់យកសុដន់ចេញ ដោយសារតែរោគមហារីសុដន់។

ប្រាក់សំណងនេះអាចទាមទារសុំយកបានសំរាប់ថ្លៃសុដន់សិប្បនិម្មិតថ្មី ឬផ្លាស់ថ្មីដែលទិញចាប់ពីថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2008 ។

## តើខ្ញុំមានសិទ្ធិទទួលឬទេ?

ស្ត្រីទាំងអស់ដែលជាអ្នករស់នៅជាអចិន្ត្រៃយ៍ក្នុងប្រទេសអូស្ត្រាលី មានសិទ្ធិទទួល Medicare និងមានការវះកាត់យកសុដន់ចេញដោយសារតែរោគមហារីក មានសិទ្ធិទាមទារសុំប្រាក់សំណងនេះ។

## តើខ្ញុំទាមទារសុំប្រាក់សំណងនេះតាមវិធីណា?

ដើម្បីទាមទារសុំប្រាក់សំណងនេះ អ្នកនឹងត្រូវបំពេញពាក្យទាមទារសុំប្រាក់មួយ។ ពាក្យនេះមាននៅឯការិយាល័យ Medicare ឬតាមវ៉ិបសាយ **www.medicareaustralia.gov.au**

នៅពេលដែលអ្នកបានសរសេរបំពេញក្រដាសទាមទារសុំប្រាក់នេះហើយ សូមភ្ជាប់ជាមួយនូវបង្កាន់ដៃរបស់អ្នក ហើយប្រគល់វាទៅឲ្យការិយាល័យ Medicare ឬផ្ញើទៅកាន់៖

**Medicare Australia**
**GPO Box 9822**
នៅក្នុងរដ្ឋធានីរបស់អ្នក

### តើប្រាក់សំណងមានចំនួនប៉ុន្មាន?

ប្រាក់សំណងរហូតដល់ $400 សំរាប់សុដន់សិប្បនិម្មិតថ្មី ឬផ្លាស់ថ្មីនីមួយៗ អាចផ្តល់ឲ្យដោយផ្អែកលើតម្លៃនៃសុដន់សិប្បនិម្មិតនោះ។ ការអនុវត្តនេះគឺចំពោះសុដន់សិប្បនិម្មិតនីមួយៗ សំរាប់សុដន់នីមួយៗ។

### តើខ្ញុំអាចទាមទារសុំប្រាក់សំណងបានប៉ុន្មានដង?

បើអ្នកបានទាមទារសុំប្រាក់សំណងនៅក្រោមកម្មវិធីនេះរួចហើយនោះ អ្នកអាចទាមទារសុំប្រាក់សំណងបន្ថែមទៀតនៅពេលមិនឲ្យតិចជាងពីរឆ្នាំក្រោយមកទៀត ចាប់ពីថ្ងៃទិញកាលពីគ្រាមុននោះទេ។ ការអនុវត្តនេះគឺចំពោះសុដន់សិប្បនិម្មិតនីមួយៗ សំរាប់សុដន់នីមួយៗ។

### តើគេនឹងប្រគល់ប្រាក់សំណងនេះតាមវិធីណា?

ប្រាក់សំណងទាំងអស់នឹងត្រូវគេដាក់ចូលទៅក្នុងគណនីធនាគារ ដែលអ្នកស្នើឲ្យដាក់នៅក្នុងពាក្យទាមទារសុំប្រាក់របស់អ្នក។ យើងនឹងផ្ញើជូនអ្នកនូវរបាយការណ៍មួយ ដែលប្រាប់នូវចំនួនប្រាក់ដែលដាក់ចូលក្នុងគណនីរបស់អ្នក ដែលអាចរក្សាទុកសំរាប់គោលបំណងពន្ធដារ។

## ដើម្បីទទួលព័ត៌មានបន្ថែម

| | |
|---|---|
| វិបសាយ | **www.medicareaustralia.gov.au** |
| ទូរស័ព្ទ | **132 011*** |
| TTY | **1800 552 152**** (សំរាប់អ្នកមានពិការភាពខាងស្តាប់ ឬនិយាយ) |
| TIS | **131 450*** (សំរាប់អ្នកមានពិការភាពខាងស្តាប់ ឬនិយាយ) |

*គិតថ្លៃទូរស័ព្ទ។

**គិតថ្លៃទូរស័ព្ទចេញពីទូរស័ព្ទចល័ត និងទូរស័ព្ទដែលត្រូវបង់ថ្លៃសំរាប់ប្រើប៉ុណ្ណោះ។

1577_12f.04.11.09